**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

JS LAND PLC

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**
លេខ: ២០២៤/០០២/ស.ម.ក ជ.អ.ល.

# សេចក្ដីជូនដំណឹង
# ស្ដីពី
# កិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២ របស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី

**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី** (ជ.អ.ល.) មានកិត្តិយសសូមជម្រាបជូនភាគហ៊ុនិកទាំងអស់ ដោយយោងតាមកិច្ចប្រជុំក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី ដែលបានប្រព្រឹត្តឡើងនៅថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០២៤ ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី នឹងធ្វើការរៀបចំកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២ តាមការកំណត់ដូចខាងក្រោម៖

១. កាលបរិច្ឆេទកំណត់ទុក៖ **ថ្ងៃទី ១៣ ខែឧសភា ឆ្នាំ ២០២៤**

២. កាលបរិច្ឆេទប្រារព្ធកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៖ **ថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០២៤ វេលាម៉ោង ៩:០០ ព្រឹក**

៣. ទីកន្លែងនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២៖

ក. ទីកន្លែងប្រជុំ៖ សណ្ឋាគារ ហ្វែរហ្វៀល បាយ ម៉ារៀត ភ្នំពេញ (Fairfield by Marriott Phnom Penh) សាលប្រជុំ Ballroom ជាន់ទី២៥ ដែលមានទីតាំងស្ថិតនៅ មហាវិថី សហព័ន្ធរុស្ស៊ី ភូមិ ១០ សង្កាត់ផ្សារដេប៉ូទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ខ. សន្និសិទតាមរយៈអនឡាញ Zoom

៤. របៀបវារៈនៃកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២ រួមមាន៖

**ក. របាយការណ៍ស្ដីពីអាជីវកម្មប្រចាំឆ្នាំ ២០២៣**

i. របាយការណ៍នៃការអភិវឌ្ឍគម្រោង

ii. របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ២០២៣

**ខ. ការបែងចែកភាគលាភ**

i. សំណើនៃការបែងចែកភាគលាភ ក្នុងឆ្នាំ២០២៣

**គ. របាយការណ៍ស្ដីពីផែនការអនាគតរបស់ក្រុមហ៊ុន**

**១. ផែនការអភិវឌ្ឍន៍អាជីវកម្ម**

i. ការបើកដំណើរការនៃ The Garden Residency 3 (TGR3)

ii. គម្រោងឧស្សាហកម្ម

iii. អាជីវកម្មទៅលើការជួល និងការលក់រាយ

**២. គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ**

i. ក្រុមហ៊ុន ដេអេស វេនឈ័រ ឯ.ក+ ជាមួយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ អិល ស៊ី អេច

**ឃ. សេចក្តីសម្រេចការបោះឆ្នោត**

i. ការអនុម័តតែងតាំងលើកាបន្តអាណត្តិ ឧកញ៉ា ម៉េង លី ជាអភិបាលមិនប្រតិបត្តិ របស់ក្រុមហ៊ុន ដេអេស លែន ភីអិលស៊ី រយៈពេល៣ (បី) ឆ្នាំបន្ថែមទៀត

ii. ការអនុម័តតែងតាំងលើការបន្តអាណត្តិ លោក Tang Chun Kiu ជាអភិបាលមិនប្រតិបត្តិ របស់ក្រុមហ៊ុន ដេអេស លែន ភីអិលស៊ី រយៈពេល៣ (បី) ឆ្នាំបន្ថែមទៀត

iii. ការអនុម័តលើការធ្វើវិសោធនកម្មលើមាត្រា ១៧.៥ និងឧបសម្ព័ន្ធ ៣ (បញ្ជីនៃសមាជិកក្រុមប្រឹក្សាភិបាល) នៃលក្ខន្តិកៈ របស់ក្រុមហ៊ុន ដេអេស លែន ភីអិលស៊ី

ម្ចាស់ភាគហ៊ុនដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិកនៅថ្ងៃទី **១៣ ខែឧសភា ឆ្នាំ ២០២៤** (កាលបរិច្ឆេទកំណត់ទុក) នឹងទទួលបានលិខិតអញ្ជើញតាមរយៈសារអេឡិចត្រូនិកពី **ធនាគារអេស៊ីលីដា ភីអិលស៊ី** (ភ្នាក់ងារផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ ដ.អ.ល) **ចាប់ពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០២៤។**

បន្ទាប់ពីទទួលបានលិខិតអញ្ជើញតាមរយៈសេចក្តីជូនដំណឹងខាងលើ សូមភាគហ៊ុនិកទាំងអស់មេត្តាបញ្ជាក់អំពីការចូលរួមទៅកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** តាមរយៈសារអេឡិចត្រូនិក ឬលេខទំនាក់ទំនង ដូចបានបញ្ជាក់ជូនខាងក្រោម **ចាប់ពីថ្ងៃទី ២៤ ខែឧសភា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០២៤។**

ក្នុងករណីដែលភាគហ៊ុនិកណាមួយមិនអាចចូលរួមក្នុងកិច្ចប្រជុំភាគហ៊ុនិកដោយផ្ទាល់បាន ភាគហ៊ុនិកអាចតែងតាំងបុគ្គលណាមួយផ្សេងទៀតដែលជាអ្នកតំណាងរបស់ភាគហ៊ុនិកដើម្បីចូលរួមក្នុងកិច្ចប្រជុំ។ ទម្រង់អណត្តិគាហកៈត្រូវបានផ្ញើទៅភាគហ៊ុនិករួមជាមួយនឹងសេចក្តីជូនដំណឹងស្តីពីកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញ។ ភាគហ៊ុនិក ឬអ្នកកាន់ទម្រង់អណត្តិគាហកៈត្រូវដាក់បញ្ជូនទម្រង់នោះតាមរយៈមធ្យោបាយអេឡិចត្រូនិចទៅកាន់ភ្នាក់ងារចុះបញ្ជីមូលបត្រ ផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ **ធនាគារអេស៊ីលីដា** ចាប់ពីថ្ងៃទី **២៤ ខែឧសភា ឆ្នាំ ២០២៤ ដល់ថ្ងៃទី ២ ខែមិថុនា ឆ្នាំ ២០២៤។**

ភាគហ៊ុនិកដែលមិនបានបញ្ជាក់ពីវត្តមានការចូលរួម ឬមិនបានផ្តល់ទម្រង់អណត្តិគាហកៈទៅកាន់ភ្នាក់ងារចុះបញ្ជីមូលបត្រ ផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់របស់ **ធនាគារអេស៊ីលីដា** តាមការកំណត់ខាងលើ នឹងមិនត្រូវបានអនុញ្ញាតចូលរួមក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញនោះទេ។

- **បញ្ជាក់៖ ភាគហ៊ុនិកដែលអញ្ជើញចូលរួមកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២ សូមភ្ជាប់មកជាមួយនូវលិខិតអញ្ជើញដែលបានប្រគល់/ផ្ញើជូន ដើម្បីចុះវត្តមានក្នុងកិច្ចប្រជុំមហាសន្និបាតភាគហ៊ុនិកសាមញ្ញលើកទី២ របស់ក្រុមហ៊ុន ដេអេស លែន ភីអិលស៊ី។**

សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនងមកកាន់ **ធនាគារ អេស៊ីលីដា ភីអិលស៊ី** និង **ជេអេស លែន ភីអិលស៊ី** តាមរយៈអាសយដ្ឋាន និងលេខទំនាក់ទំនងដូចខាងក្រោម៖

**១. ធនាគារ អេស៊ីលីដា ភីអិលស៊ី**

- អាស័យដ្ឋាន: ជាន់ទី៥ ផ្ទះលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ
- ទូរស័ព្ទ: (៨៥៥) ២៣ ៩៩៨ ៧៧៧
- ទូរសារ: (៨៥៥) ២៣ ៩៩៨ ៦៦៦
- ទូរស័ព្ទដៃ: (៨៥៥) ១៥ ៩០០ ៥៣៨ (Ext: ០៥០២១)<br>(៨៥៥) ១៥ ៨០០ ៦៦៣<br>(៨៥៥) ៧០ ៥០០ ៣៧៧
- សារអេឡិចត្រូនិក: huot.sophy@acledabank.com.kh

**២. ជេអេស លែន ភីអិលស៊ី**

- អាស័យដ្ឋាន: អគារអ៊ីឡេសេកោះពេជ្រ, ផ្លូវ កោះពេជ្រ, សង្កាត់ទន្លេបាសាក់, ខណ្ឌចំការមន, រាជធានីភ្នំពេញ
- ទូរស័ព្ទដៃ: ០១០ ៨៨ ៦៦ ៩៩
- សារអេឡិចត្រូនិក: info@jslandplc.com

ថ្ងៃអង្គារ ១៥ កើត ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស. ២៥៦៧<br>
រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២៤<br>
**ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ជេអេស លែន ភីអិលស៊ី JS LAND PLC. KINGDOM OF CAMBODIA

**ចម្លងជូន៖**

- និយ័តករមូលបត្រកម្ពុជា **(ន.ម.ក)**
- ក្រុមហ៊ុនផ្សារមូលបត្រកម្ពុជា **(ផ.ម.ក)**
- សមាជិកក្រុមប្រឹក្សាភិបាលរបស់ **ជ.អ.ល**
- ក្រុមហ៊ុន **ហ្វ្រែន ថនតុន** (សវនករឯករាជ្យរបស់ **ជ.អ.ល**)
- ធនាគារអេស៊ីលីដា (ភ្នាក់ងារចុះបញ្ជីមូលបត្រ ផ្ទេរមូលបត្រ និងភ្នាក់ងារទូទាត់) របស់ក្រុមហ៊ុន **ជ.អ.ល**